BMI0185

# សម្ភាសន៍ជាមួយឈ្មោះ យ៉ត សម្បត្តិ ភេទស្រី អាយុ៥២ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ «កម្មករត្រពាំងថ្ម»

## សព្វថ្ងៃរស់នៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឌី សុជាតា និង វ៉ាន់ថាន់ ពៅដារ៉ា

០០:១៩:៥៦

១១ទំព័រ

ជាតា ៖ មីងខ្ញុំសុំសួរឈ្មោះមីង តើមីងឈ្មោះអីគេ?

សម្បត្តិ ៖ ខ្ញុំឈ្មោះ សម្បត្តិ ។

ជាតា ៖ យ៉ត សម្បត្តិ មីងអាយុប៉ុន្មានហើយមីង?

សម្បត្តិ ៖ ខ្ញុំទើបតែ៥២ សម័យអាពត ខ្ញុំ១៧-១៨ ខ្ញុំមិនសូវចាំបានទេ វានៅក្មេងអីចឹងមិនបាន រៀនបានសូត្រ ។

ជាតា ៖ អីចឹងមីងរៀនដល់ថ្នាក់ទីប៉ុន្មាន?

សម្បត្តិ ៖ អត់ អត់បានសោះ មិនដែលស្គាល់សាលាណាបន្តិចទេ ។

ជាតា ៖ ចុះមីងមានបងប្អូនប៉ុន្មាននាក់មីង?

សម្បត្តិ ៖ ខ្ញុំបងប្អូនខ្ញុំសព្វថ្ងៃនៅបីនាក់ ។

ជាតា ៖ ចុះបងប្អូនមីងពិតប្រាកដ ។

សម្បត្តិ ៖ ប៉ុណ្ណេះឯង ប្អូននាក់ងាប់អស់ម្នាក់ ។

ជាតា ៖ ម្នាក់ហ្នឹងម៉េចបាន?

សម្បត្តិ ៖ គាត់ទើបខូចបានពីរឆ្នាំ ។

ជាតា ៖ អូ! អីចឹង ។ ហើយមីងមានកូនអីប៉ុន្មាននាក់ដែរ?

សម្បត្តិ ៖ កូន៦ ។

ជាតា ៖ មីងមានគ្រួសារហើយអី?

សម្បត្តិ ៖ គ្រួសារខ្ញុំលែងគ្នាប៉ុន្មានដប់ឆ្នាំ ១៦ឆ្នាំ ។

ជាតា ៖ គាត់ឈ្មោះអីគេមីង?

សម្បត្តិ ៖ គាត់ឈ្មោះ ណាង ។

ជាតា ៖ ហើយមីងមានកូន៦នាក់?

សម្បត្តិ ៖ ចាស!

ជាតា ៖ មីងមានឪពុកម្ដាយ ឪពុកមីងឈ្មោះអីគេ?

សម្បត្តិ ៖ គាត់ខូចសម័យអាពតអស់ហើយ ។

ជាតា ៖ ចាស! គាត់ឈ្មោះអីទៅ?

សម្បត្តិ ៖ គាត់ឈ្មោះ យ៉ត នួន ។

ជាតា ៖ យ៉ត ។

សម្បត្តិ ៖ យ៉ត នួន ។

ជាតា ៖ ចុះម្ដាយមីង?

សម្បត្តិ ៖ ម្ដាយខ្ញុំគាត់ខូចសម័យអាពត ។

ជាតា ៖ គាត់ឈ្មោះអីទៅមីង?

សម្បត្តិ ៖ គាត់ឈ្មោះ ធន់ ។

ជាតា ៖ ធន់ ។ គាត់ទាំងពីរនាក់គាត់មានបញ្ហាអីបានគាត់ស្លាប់នៅក្នុងសម័យហ្នឹងមីង?

សម្បត្តិ ៖ សម័យហ្នឹងអត់ ។

ជាតា ៖ ដូចថា?

សម្បត្តិ ៖ ដូចថានៅតាមភូមិហូបបបរបានមួយស្លាបព្រា គេចែកមួយវែក បានមួយស្លាព្រាទៅ ។

ជាតា ៖ ចុះឪពុកមីងស្លាប់ដោយសារអីដែរមីង?

សម្បត្តិ ៖ ទេ គាត់ចាស់ក៏ខូចខ្លួនគាត់ទៅ ។

ជាតា ៖ ខូច គ្រាន់តែគាត់ខូច ដោយជរានៅក្នុងសម័យហ្នឹង?

សម្បត្តិ ៖ ចាស!

ជាតា ៖ ចុះដល់ពេលម្ដាយមីងវិញ?

សម្បត្តិ ៖ ម្ដាយខ្ញុំគាត់ខូចចាស់ដែរ ។

ជាតា ៖ អីចឹងមិនមែនគាត់ខូចដោយសារអត់អាហារអត់អីទេ?

សម្បត្តិ ៖ អត់ទេ ខូចចាស់ ។ វាអត់ហ្នឹងឯងបានជាខូច កាលណោះលំបាកណាស់ មិនមានគ្រប់គ្រាន់ដូចយើងសព្វថ្ងៃ ស៊ីតែបន្លែ ។

ជាតា ៖ ពេលនៅក្នុងអាចាប់ផ្ដើមបែកក្លាមឆ្នាំ៧៥ហ្នឹងមីងធ្វើអីទៅមីង?

សម្បត្តិ ៖ ដែលអាពតបែកទៅហ្នឹង?

ជាតា ៖ អាពតចូលមកណា?

សម្បត្តិ ៖ ចូលមក?

ជាតា ៖ ចាស!

សម្បត្តិ ៖ អត់មានធ្វើអីទេ ធ្វើតែស្រែបន្តិចបន្តួច ។

ជាតា ៖ ដល់ពេលគេចូលមក គេដូចថាចូលមកដល់ភ្លាមគេធ្វើយ៉ាងម៉េច មីងកំពុងតែធ្វើអី ហើយគេមកប្រាប់មីងថាម៉េច?

សម្បត្តិ ៖ អូ! គេប្រាប់ថាឲ្យយើងជម្លៀសចេញទៅរៀលនោះ ចេញទៅឆ្ងាយតើសនាង ចេញទៅភ្នំកូនដំរី គេឲ្យយើងទៅនៅណោះមួយរយៈ បានគេរើសដូចថាអ្នកណាធំៗ ធំដូចខ្ញុំអីចេះ អាយុ១៤-១៥គេយកទៅឲ្យធ្វើនារីលើកទំនប់ឯកូនខ្មែរ ។

ជាតា ៖ កូនខ្មែរ ។ ដំបូងមីងទៅ ជម្លៀសឲ្យមីងទៅស្រុកអីគេមីញ?

សម្បត្តិ ៖ ទៅភ្នំកូនដំរី ។

ជាតា ៖ កូនដំរី?

សម្បត្តិ ៖ ចាស!

ជាតា ៖ នៅកូនដំរីហ្នឹងប្រហែលប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

សម្បត្តិ ៖ មួយខែជាងនាងអើយ គេឲ្យយើងនៅនោះឯង ណោះឯងបានបំបែកជាក្រុមៗ ។ ដល់ខ្ញុំធំអីចេះទៅ យើងទៅលើកទំនប់ ។

ជាតា ៖ អីចឹងចេញពីកូនដំរីហ្នឹងទៅមីងទៅនៅស្រុកអីគេដែរ?

សម្បត្តិ ៖ ខ្ញុំទៅលើកទំនប់ ។

ជាតា ៖ ត្រពាំងថ្ម?

សម្បត្តិ ៖ ទំនប់ត្រពាំងថ្ម ចាស!

ជាតា ៖ អីចឹងមីងចេញពីមួយខែទៅ ទៅនៅត្រពាំងថ្មភ្លាម?

សម្បត្តិ ៖ ចាស!

ជាតា ៖ មីងទៅនៅក្នុងកងណាមីង?

សម្បត្តិ ៖ អត់ស្គាល់ទេ ខ្ញុំមិនសូវចាំបានទេ គេឲ្យលើកចេះតែលើកទៅណា ។

ជាតា ៖ អីចឹងពេលហ្នឹងមីងនៅជាយុវជន ឬកុមារ?

សម្បត្តិ ៖ ខ្ញុំ?

ជាតា ៖ ចាស!

សម្បត្តិ ៖ កាលហ្នឹងខ្ញុំអាយុ១៨ហើយ ។

ជាតា ៖ ចាស!

សម្បត្តិ ៖ មិនទាន់ដឹងអីទេ ។

ជាតា ៖ ប៉ុន្តែក្រុមមីងហ្នឹងនៅក្រុមរបៀបជាក្រុមកុមារ ឬរបៀបម៉េច ពេលអាយុ១៨ហ្នឹង?

សម្បត្តិ ៖ នារីគេចុះនារីហើយ ។

ជាតា ៖ នារី?

សម្បត្តិ ៖ ចាស!

ជាតា ៖ មីងអាចដឹងថានារីហ្នឹងនារីតំបន់ ឬនារី?

សម្បត្តិ ៖ នារីគេឲ្យទៅលើកទំនប់ទើបបានបាយនាង នៅតាមជាមួយម៉ែឪនេះគេអត់ឲ្យបាយយើងហូបទេ ម៉ែឪយើងណោះនៅភូមិណោះទុកទេ យើងណោះក៏ទៅរាប់ខែអីចេះទៅនាង ។ មិនមែនរាប់ខែទេ សឹងថារាប់ឆ្នាំ បីឆ្នាំប្រាំបីខែនេះឯងគិតមើល មិនដែលមកជួបម្ដាយសោះទាល់តែអាពតវាចេញទៅបានយើងហ៊ានចេញមកភូមិមកស្រុក មកហើយមិនឃើញម៉ែឪយើងនៅផ្ទះទៀត នោះគេជម្លៀសទៅកូនដីរអស់ ។

ជាតា ៖ មីងនៅត្រពាំងថ្មហ្នឹងប្រហែលរយៈពេលប៉ុន្មានដែរមីង?

សម្បត្តិ ៖ នៅប្រហែលជាបីខែ ជីករួចហើយបានគេបញ្ជូនឲ្យយើងមកដកសំណាបវិញ ។

ជាតា ៖ ពេលមីងនៅត្រពាំងថ្មហ្នឹង គេឲ្យមីងធ្វើអីគេខ្លះ?

សម្បត្តិ ៖ លើកតែទំនប់ លើកដូចថាយើងទៅមុនដំបូងណាគេដាក់យើងមួយម៉ែត្រគូបកន្លះ ដល់តែយើងលើករួច គេដាក់យើងកន្លះម៉ែត្រគូបទៀត វាពីរម៉ែត្រ ។

ជាតា ៖ ដំបូងគេឲ្យយើងមួយម៉ែត្រគូប?

សម្បត្តិ ៖ ចាស!

ជាតា ៖ ចុះប្រហែលប៉ុន្មានខែបានគេដំឡើងឲ្យទៀត?

សម្បត្តិ ៖ អត់ទេនាង យើងលើកថ្ងៃនេះរួចណា ស្អែកឡើងគេថែមឲ្យយើងទៀត គេមិនឲ្យយើងសម្រាកទេ គេឲ្យយើងធ្វើជាប់ ។

ជាតា ៖ អីចឹងសរុបទៅមីងធ្វើមួយថ្ងៃប៉ុន្មានម៉ែត្រគូប?

សម្បត្តិ ៖ បើរួចគេដាក់ឲ្យយើងបីម៉ែត្រគូប បើយើងខំក៏រួច បើយើងមិនខំគេអង្គុយមើលយើងហ្នឹងឯង ។

ជាតា ៖ អីចឹងរយៈពេលបីខែដែលមីងនៅហ្នឹង លើកមួយថ្ងៃបីម៉ែត្រគូប?

សម្បត្តិ ៖ ចាស! បីម៉ែត្រគូប ។

ជាតា ៖ ចុះការហូបចុកអីម៉េចដែរមីង?

សម្បត្តិ ៖ ហូបមិនឆ្អែតទេនាងវាចេះតែទៅអីចេះ បើយើងមិនទៅ យើងធ្វើជាឈឺជាអីគេមើលយើង តាមដានយើង មិនឲ្យយើងនៅនឹងខ្ទមទេ ។

ជាតា ៖ តាមដានម៉េចទៅ?

សម្បត្តិ ៖ តាមដានយើងថាយើងឈឺពិតប្រាកដ ឬមិនពិតប្រាកដ អីចឹងឯងសព្វថ្ងៃនេះ ។

ជាតា ៖ ដូចរបបអាហារអីចឹង គេឲ្យយើងហូបបាយ ឬក៏ហូបបបរ?

សម្បត្តិ ៖ ហូបបបររប៉ិៗ ។

ជាតា ៖ មួយថ្ងៃប៉ុន្មានចានមីង?

សម្បត្តិ ៖ មួយថ្ងៃបីពេល ។

ជាតា ៖ មួយថ្ងៃបីពេល ហើយមួយពេលប្រហែលប៉ុន្មានទៅ?

សម្បត្តិ ៖ កូនដួលយើងប៉ុណ្ណេះ ។

ជាតា ៖ អីចឹងមីងបានហូបបីពេល ចុះម៉ោងធ្វើការអីម៉េចទៅ គេចែកចូលលើកដីម៉ោងប៉ុន្មាន?

សម្បត្តិ ៖ បើយើងឈប់១១អីចេះ មក១ចុះទៀតហើយ ។

ជាតា ៖ ចូលពេលព្រឹកម៉ោងប្រហែលប៉ុន្មានមីង?

សម្បត្តិ ៖ ម៉ោង៦ ។

ជាតា ៖ ចាស! ចូលម៉ោង៦ ចេញម៉ោង ១០ ១១?

សម្បត្តិ ៖ ចាស!

ជាតា ៖ ហើយចូលម៉ោងប៉ុន្មានវិញមីង?

សម្បត្តិ ៖ បើល្ងាចយើងហូបបាយហូបអីរួចហើយ គេដាក់ឲ្យយើងមួយម៉ែត្រគូប ។

ជាតា ៖ អីចឹងចូលធ្វើការ ពេលសម្រាកហូបបាយថ្ងៃហ្នឹងប្រហែលប៉ុន្មានម៉ោង?

សម្បត្តិ ៖ មិនបានមួយម៉ោងផង កន្លះម៉ោងហ្នឹង ។

ជាតា ៖ ចាស!

សម្បត្តិ ៖ ចុះយើងខ្លាចមិនរួចនោះ ។

ជាតា ៖ ចាស! ហើយអីចឹងដល់ល្ងាចម៉ោងប៉ុន្មានបានចេញវិញ?

សម្បត្តិ ៖ ហូបបបរហូបអីរួចទៅម៉ោង៧អីចេញធ្វើការទៀត គេដាក់ភ្លើងឲ្យយើង ។

ជាតា ៖ អីចឹងអាហ្នឹងត្រឹមម៉ោង៧ អាហ្នឹងហើយប្រហែលបីម៉ែត្រគូបហ្នឹងហើយ?

សម្បត្តិ ៖ ម៉ោង១០ ១១យប់អ៊ីរួចហើយ បើមិនរួចគេត្រូវឲ្យមកដេក គេឲ្យយើងបង្ហើយថ្ងៃទៀត ។

ជាតា ៖ ពេលម៉ោង៧ហ្នឹងមីងធ្វើហើយអត់មីង?

សម្បត្តិ ៖ អត់ហើយទេ ។

ជាតា ៖ អ៊ីចឹងធ្វើដល់យប់ម៉ោង១០បានហើយ?

សម្បត្តិ ៖ ចាស! បើហើយ មិនហើយនោះត្រូវអាណារួចគេឲ្យឡើងមកជាមួយគ្នា ។

ជាតា ៖ ចុះបើដល់ម៉ោង១០ហើយយើងអត់ហើយ ម៉េចវិញ?

សម្បត្តិ ៖ យើងបង្ហើយថ្ងៃក្រោយព្រឹកឡើង ។

ជាតា ៖ គេទុកពេលឲ្យយើងបង្ហើយទៀតអី?

សម្បត្តិ ៖ ចាស!

ជាតា ៖ ចុះទឹក ដូចរបៀបហូបទឹកអ៊ីចឹងហូបតុម៉េចទៅមីង?

សម្បត្តិ ៖ យ៉ាប់ណាស់ ទឹកប្អូនប្រាំថ្ងៃមិនដែលបានផ្ទួតម្តង តែពព្រឹងមិនដែលបានផ្ទួតទេ ។

ជាតា ៖ មីងទៅលើកហ្នឹងទំនប់ត្រពាំងថ្មហ្នឹងគេមានចែកស្ពាន ពីរបីស្ពានដូចជាអ៊ីចឹងអី ហើយមីង មានដឹងថាលើកនៅម្តុំណាទេ?

សម្បត្តិ ៖ ខ្ញុំនៅពី នៅឯជើងគល់ ហ៊ុ! នៅឯជើងត្រពាំងថ្ម ។

ជាតា ៖ ខាងជើងត្រពាំងថ្មហ្នឹង ស្រុកអីគេដែរមីង?

សម្បត្តិ ៖ ជិតភ្នំកូនខ្មែង ។

ជាតា ៖ ចាស!

សម្បត្តិ ៖ ទៅពីត្រពាំងថ្ម ទំនប់ត្រពាំងថ្មទៅជាប់ក្នារអើន ខ្ញុំលើកស្ពានទីមួយ ។

ជាតា ៖ អ៊ីចឹងម្តុំហ្នឹងអត់មានទឹកមានអីគ្រប់គ្រាន់ទេ?

សម្បត្តិ ៖ អត់ទេ មិនមានទឹកសោះ ។

ជាតា ៖ ហើយដល់ពេលទឹកហូបអី គេចែកឲ្យ ឬក៏?

សម្បត្តិ ៖ ទឹកហូបគេដាក់ឲ្យទៅដាំបាយដាំទឹក គេចាត់មនុស្សឲ្យទៅដឹកទឹក ។

ជាតា ៖ ចុះទឹកមីងផ្ទួតខ្លួនឯង?

សម្បត្តិ ៖ តែទឹកផ្ទួតអត់មានទេ ទឹកហូបមានគេឲ្យ ។

ជាតា ៖ គេចែកឲ្យ?

សម្បត្តិ ៖ ចាស!

ជាតា ៖ មួយថ្ងៃគេឲ្យប៉ុន្មានទៅមីង?

សម្បត្តិ ៖ មួយថ្ងៃមួយដបពីរដបម្នាក់ទៅ អាទឹកដូតអត់សោះ ។

ជាតា ៖ ចាស! ចុះពេលអត់មានដូតទឹកដូតអីចឹង គាត់មានឈឺមានអីទេ?

សម្បត្តិ ៖ ឈឺនាង ទាស់ខ្លះទៅណាក៏ហើម ខ្លះក៏គ្រុនញាក់ ខ្លះដឹកមកពេទ្យទាន់ មិនទាន់ក៏ងាប់ ។

ជាតា ៖ ច្រើនទេមីង?

សម្បត្តិ ៖ អូ! ច្រើនណាស់នាងអើយ ។

ជាតា ៖ មើលមីងទៅប្រហែលបីខែហ្នឹងស្លាប់ប្រហែលប៉ុន្មាននាក់?

សម្បត្តិ ៖ អូ! ច្រើនណាស់នាងអើយ ច្រើនតែអ្នកថ្មីហ្នឹងងាប់ ។

ជាតា ៖ អាចនិយាយបានថាចំនួនប្រហែលប៉ុន្មានដែរមីង?

សម្បត្តិ ៖ អានោះយកយើងទៅវ៉ៃចោលដាក់ទំនប់នេះ យកទៅ អ្នកដឹកដីយកទៅកប់ទៅ ។

ជាតា ៖ អីចឹងក្រុមមីងមានបាត់សមាជិកច្រើន?

សម្បត្តិ ៖ បាត់តែអ្នកថ្មី អ្នកចាស់មិនសូវមានទេ គេធ្វើបាបតែអ្នកថ្មី ។

ជាតា ៖ អីចឹងក្រុមមីងប្រហែលគ្នាប៉ុន្មាននាក់ទៅមីងមួយក្រុមហ្នឹង?

សម្បត្តិ ៖ មួយក្រុមតែ១២នាក់ ១០នាក់ទេ ។

ជាតា ៖ ពេលមីងធ្វើនៅហ្នឹងដែលឃើញអ្នកដែលខុសនៅមុខៗអីគេសម្លាប់អីនៅមុខទេ?

សម្បត្តិ ៖ ឃើញនាង គេទាញយកទៅវ៉ៃចោលនឹងមុខ បានជាយើងខ្លាចយើងធ្វើការឲ្យគេណានាង បើយើងមិនខ្លាចអីចុះងាប់ បានខំធ្វើការ ។ ទាញយកទៅវ៉ៃចោលភូសៗណា ។

ជាតា ៖ នៅមុខៗ?

សម្បត្តិ ៖ ចាស!

ជាតា ៖ នៅមុខអ្នកធ្វើការទាំងអស់ ។

សម្បត្តិ ៖ ផសៗ សម័យអាពតតែខុសអីនាងអើយ តែត្រប់មួយ ពងមាន់មួយក៏វ៉ៃចោលដែរ ។ ខ្ញុំស៊ីតែត្រួយដំឡូងមីពីសម័យអាពត ត្រួយដំឡូងមី និងត្រួយក្ដឹង ។

ជាតា ៖ ចុះមីងដើររកហូបអីចឹង បើគេឃើញអី?

សម្បត្តិ ៖ អត់ទេ ទាល់តែខានដូចថាយើងស៊ីបាយបបររួចហើយណា ទៅហើយនាង ទៅបេះបានមួយក្អែតទៅក៏គេហៅវ៉ៃជួងទៀតទៅ យើងគិតទៅធ្វើការទៀតទៅ ។

ជាតា ៖ ចាស! ចុះពេលដែលមីងនៅហ្នឹងប្រហែលបីខែហ្នឹង មេក្រុមមីងមានប្ដូរអត់ មានប្ដូរមនុស្ស?

សម្បត្តិ ៖ អត់មានទេ អត់ទេ ប៉ុន្តែខ្ញុំមិនស្គាល់គេ មិនសូវស្គាល់គេទេ តែវ៉ៃជួនខ្ញុំក៏ទៅធ្វើការ ខ្ញុំនៅក្មេងផងមិនសូវដឹងអីផងសម័យអាពត ។

ដារ៉ា ៖ មីងទៅទំនប់ទៅលើកដីនៅទំនប់ត្រពាំងថ្មហ្នឹងលើកនៅហ្នឹងរហូតម៉ង ឬយ៉ាងម៉េច?

សម្បត្តិ ៖ ទេ លើករួចគេបញ្ជូនខ្ញុំមកភ្នំស្អីត្រង់ណោះ ភ្នំល្វៀប ។

ដារ៉ា ៖ ភ្នំល្វៀប?

សម្បត្តិ ៖ ចាស! គេឲ្យខ្ញុំមកស្ទូងដកសំណាប ។

ដារ៉ា ៖ នៅភ្នល្វៀបហ្នឹង នៅក្នុងភូមិអី ឃុំអី ។

សម្បត្តិ ៖ នៅហ្នឹងអូល្វៀបតែម្តង ។

ដារ៉ា ៖ នៅភូមិអូល្វៀបអី?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ អាហ្នឹងនៅជាសហករណ៍ ឬយ៉ាងម៉េចដែរ?

សម្បត្តិ ៖ ខ្ញុំនៅក្នុងក្រុមគេដាំបាយដាំទឹកឲ្យយើងហូបហ្នឹង ។

ដារ៉ា ៖ នៅក្នុងជាកងនារីដដែល?

សម្បត្តិ ៖ ចាស! កងនារីដដែល ។

ដារ៉ា ៖ តែគ្រាន់តែមកនៅក្នុង?

សម្បត្តិ ៖ ចាស! ខាងដកស្ទូងវិញ ។

ដារ៉ា ៖ អីចឹងមានន័យថា បានលើកទំនប់អាងត្រពាំងថ្មរួចរាល់ហើយអីចឹង?

សម្បត្តិ ៖ បើជិតរួចហើយ គេទុកតែខ្លះទេបំបែកក្រុមមកណោះទៀត ។

ដារ៉ា ៖ អីចឹងអី?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ បានន័យថាជិតរួចរាល់ហើយបានគេដកកម្លាំង?

សម្បត្តិ ៖ ចាស! ដកកម្លាំងមកទៀត ។ អូ! នាងអើយដល់យប់ស្រិបៗដើរតម្រង់ជួរគ្នា ដល់តែយប់មួយយប់ទល់ព្រឹកដើរទៅ ។

ជាតា ៖ គេដើរទៅណាមីង?

ដារ៉ា ៖ ដើរដូចថាគេបញ្ជូនយើងមកវិញ ពីអាងត្រពាំងថ្មមកវិញ ។

ជាតា ៖ អូ! ទោះបីជាយប់ក៏គេអត់ឲ្យសម្រាក?

សម្បត្តិ ៖ អត់ឲ្យសម្រាកទេ ។

ដារ៉ា ៖ ដើរទាំងយប់?

សម្បត្តិ ៖ ចាស! ខ្ញុំនៅល្បីថាងាប់តើស ល្បីឪពុកឪទៅ ប៉ះសុទ្ធតែពួកយោធាគេហ្នឹងគេនៅតាមចុងឈើ ឪពុកខ្ញុំទៅក៏ឃើញខ្ញុំ គាត់មកវិញភ្លាម ថាតែកូនងាប់ទៅហើយ តែគេថាកូនងាប់ហើយ ងាប់ក្នុងព្រៃនេះឯង តែឪពុកខ្ញុំសុំគេថាទៅមើលតែផ្នូរកូនខ្ញុំឲ្យតែឃើញ ។

ដារ៉ា ៖ អីចឹងដល់មកធ្វើដកស្ទូងអីច្រូតនៅភ្នំល្មៀបហ្នឹងរហូតដល់ពេលណា?

សម្បត្តិ ៖ អាពតចេញទៅ ខ្ញុំអត់បានធ្វើទៅណាឆ្ងាយទេ មកតែពីណោះហើយក៏ដកស្ទូងនេះភ្នំល្មៀបហើយក៏អាពតវាចេញ ចាស! វារត់ចេញ ខ្ញុំក៏មក មកផ្ទះ មកផ្ទះថាមានអ្នកងាប់តាមផ្លូវរដិបរដុប ស្អុមៗស្អិតៗ ។

ដារ៉ា ៖ ច្រើនទេមីង?

សម្បត្តិ ៖ ងាប់តែតាមថ្នល់ ខ្ញុំក៏ដើរមកពីរនាក់បងប្អូន ។

ដារ៉ា ៖ មីងសួរត្រឡប់ក្រោយគឺថា នៅពេលលើកទំនប់អាងត្រពាំងថ្មណា ហ្នឹងមានមនុស្សច្រើនទេលើកទំនប់មីង?

សម្បត្តិ ៖ ច្រើនណាស់ រាប់ពាន់នាក់ ។

ដារ៉ា ៖ ហើយការរស់នៅស្នាក់នៅអីម៉េចដែរនៅហ្នឹង?

សម្បត្តិ ៖ គេធ្វើខ្ទមឲ្យ ។

ដារ៉ា ៖ អីចឹងនៅជាខ្ទមជាអីចឹងអី?

សម្បត្តិ ៖ ចាស! គេធ្វើខ្ទមឲ្យ ។

ដារ៉ា ៖ ចុះមានបាំងមានអីត្រឹមត្រូវទេ?

សម្បត្តិ ៖ អត់ គ្រាន់តែម៉ាបាំងសំពត់កៅស៊ូឲ្យយើងនៅ ត្រង់ណាក៏លិច ។

ដារ៉ា ៖ អីចឹងពេលភ្លៀងមកម៉េចទៅ?

សម្បត្តិ ៖ ភ្លៀងក៏លិច ដេកហាលភ្លៀងទៅណា គរគ្នាទៅណា ។

ដារ៉ា ៖ អីចឹង?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ ចុះគេមានពេលសម្រាកមានអីទេ ឬក៏លើកជាប់រហូត?

សម្បត្តិ ៖ មានពេលសម្រាកឲ្យយើងហូបបាយ ។

ដារ៉ា ៖ មានតែពេលសម្រាកហូបបាយហ្នឹងទេ?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ នៅដូចថា នៅគ្នាច្រើនណែនតាន់តាប់អីចឹង?

សម្បត្តិ ៖ ចាស! គេក៏ក្រុមគេ ខ្ញុំក៏ក្រុមខ្ញុំទៅ ។

ដារ៉ា ៖ វាមិនគគ្រិចអីចឹងទៅ?

សម្បត្តិ ៖ អូ! និយាយពីរុយ រុយនិយាយពីរុយមហាសែនដែរហ្នឹង អាអ្នកចុកក្អួតក៏ក្អួតទៅ ឈឺអាអ្នកឈឺដឹកមកពេទ្យ ។ សម័យអាពតកម្មណាស់ ។

ដារ៉ា ៖ ភាគច្រើនអ្នកនៅត្រពាំងថ្មហ្នឹងឈឺរោគអីខ្លះទៅមីង?

សម្បត្តិ ៖ ច្រើនតែចុកពោះ ក្អួត ហើយគ្រុនញាក់ ។

ដារ៉ា ៖ ហើយគេមានពេទ្យមានអីដែរនៅហ្នឹងម៉េច?

សម្បត្តិ ៖ មាន ប៉ុន្តែពេទ្យឲ្យតែថ្នាំសូន ។

ដារ៉ា ៖ អីចឹង?

សម្បត្តិ ៖ ចាស! សូនខ្លះខ្មៅ ។

ដារ៉ា ៖ បាទ! ដាក់ទៅជាដែរអត់?

សម្បត្តិ ៖ ណាខ្លះមិនជា ខ្លះក៏ជាទៅ ។ អ្នកណាខ្លាំងក៏បញ្ជូនទៅពេទ្យទៅ ។

ដារ៉ា ៖ នៅកន្លែងត្រពាំងថ្មហ្នឹងមានឃើញជាអ្នកធំអ្នកតូចអីគេទៅពិនិត្យមើលអី?

សម្បត្តិ ៖ យូរៗបានគេទៅម្ដង ។

ដារ៉ា ៖ ហ្នឹងមកពីខាងណា?

សម្បត្តិ ៖ ដូចថាគេបើកឡានបើកអីទៅជប់លៀងជប់អីឲ្យប្រធានៗ ។

ដារ៉ា ៖ អីចឹង?

សម្បត្តិ ៖ ចាស!

ជាតា ៖ ទៅម្ដងប្រហែលប៉ុន្មាននាក់ទៅមីង?

សម្បត្តិ ៖ ទៅ៤-៥នាក់ទៅ ខ្លះគ្នាគេទៅ ។

ជាតា ៖ មីងមានស្គាល់ឈ្មោះអ្នកណាទេ?

សម្បត្តិ ៖ ទេមិនដែលស្គាល់ទេ គេមិនដែលឲ្យយើងដឹងណា យើងលើកទៅ យើងចេះតែធ្វើទៅឲ្យតែឃើញឡានគេមក យើងខំ ប្រធានក្រុមគេដើរប្រាប់យើង ខំណាខំ នែ! អង្គការគេមកអីចេះចុះណា

ដារ៉ា ៖ មីងភ្លេចសួរមីង ស្រុកកំណើតមីងនៅឯណា ស្រុកកំណើតកើតជា?

សម្បត្តិ ៖ នៅនេះឯង ស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ នៅភូមិ?

សម្បត្តិ ៖ ភូមិប៉ុស្តិ៍ចាស់ ។

ដារ៉ា ៖ ប៉ុស្តិ៍ចាស់តាំងពីដើមមកអីចឹងមកអី?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះយើងហ្នឹង?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ ហើយសព្វថ្ងៃនៅភូមិនេះដែរ?

សម្បត្តិ ៖ នៅនេះឯង ។

ដារ៉ា ៖ នៅភូមិប៉ុស្តិ៍ចាស់ដដែល?

សម្បត្តិ ៖ ចាស!

ដារ៉ា ៖ អីចឹងពួកខ្ញុំដូចអត់មានអីសួរមីងទៀតទេ ។ បាទ! ខ្ញុំអរគុណច្រើនមីងដែលបានផ្តល់ព័ត៌មានមីងណា ។

សម្បត្តិ ៖ ចាស!

«ចប់»